# សេចក្តីថ្លែងការណ៍

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ មិនយល់ស្របតាមសេចក្តីក្នុងសារាចររបស់ក្រសួងពត៌មាន និងក្រសួងធម្មការ ដែលតម្រូវឲ្យសុំច្បាប់និងត្រួតពិនិត្យធម៌ទេសនារបស់ព្រះសង្ឃតាមវិទ្យុនិងទូរទស្សន៍ប្រទេសកម្ពុជា

web site: hoksavann.org

តាមសារាចររបស់ក្រសួងពត៌មាននិងក្រសួងធម្មការ ចុះថ្ងៃទី២៩ វិច្ឆិកា ២០០៥ តម្រូវឲ្យសុំច្បាប់និងត្រួតពិនិត្យនូវធម៌ទេសនារបស់ព្រះសង្ឃ មុននឹងយកទៅចាក់ផ្សាយតាមវិទ្យុនិងទូរទស្សន៍ទូទាំងប្រទេសកម្ពុជាទាំងមូល ។

សូមជំទាស់នឹងសារាចរនេះដោយហេតុ ៖

១- ក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ត្រង់មាត្រា៤៣ ចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ត្រង់មាត្រា៦៩ចែងថា រដ្ឋមានកាតព្វកិច្ចថែរក្សានិងពង្រីកវប្បធម៌ជាតិ ។ ដូច្នេះការផ្សាយធម៌ទេសនានេះ ជាកាតព្វកិច្ចដែលរដ្ឋត្រូវជួយឧបត្ថម្ភ មិនត្រូវរឹតបន្តឹងឡើយ ។

២- បន្ទាប់ពីឆ្លងកាត់របបប៉ុល-ពតមក ប្រជាពលរដ្ឋខ្មែរមានសីលធម៌ធ្លាក់ចុះ ដូច្នេះរដ្ឋត្រូវការជំនួយ ពីផ្លូវពុទ្ធចក្រ គឺឲ្យព្រះសង្ឃទេសនាអប់រំប្រជាពលរដ្ឋខ្មែរ ឲ្យស្គាល់បាបបុណ្យគុណទោស ជាពិសេសអប់រំចំពោះយុវជន ដើម្បីឲ្យមានសីលធម៌ខ្ពស់ឡើងវិញ ទុកជាវិភាគទានចូលរួមជួយរាជរដ្ឋាភិបាល ដែលកំពុងអភិវឌ្ឍន៍ប្រទេសកម្ពុជា គ្រប់វិស័យ មានវិស័យសីលធម៌នេះជាដើម ។

៣- តាំងពីដើមមក ការទេសនារបស់ព្រះសង្ឃខ្មែរគ្រប់ទីកន្លែង ទោះបីតាមវិទ្យុក៏ដោយ ពុំមានការសុំច្បាប់ និងការត្រួតពិនិត្យពីរដ្ឋឡើយ ។ ប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងលោក ក៏រដ្ឋគេពុំធ្វើដូច្នេះដែរ ។

៤- ការចេញសារាចររបស់ក្រសួងធម្មការនិងក្រសួងពត៌មានបែបនេះ ជាការខុសឆ្គងខ្លាំងណាស់ បង្អាក់ដំណើរការលូតលាស់របស់ព្រះពុទ្ធសាសនា ខាងការផ្សាយ ហើយប្រឆាំងនឹងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នត្រង់មាត្រា៤១ ដែលចែងពីសិទ្ធិប

ញេញមតិ និងមិនស្រុបតាមសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សនៃអង្គ-ការសហប្រជាជាតិផង ។

៥- ក្រសួងទាំង២ដែលជាតំណាងរាជរដ្ឋាភិបាលខ្មែរ គួរសរសើរលើកទឹកចិត្តចំពោះលោកអ្នក ដែលបាននិមន្តព្រះសង្ឃ និងអ្នកប្រាជ្ញព្រះពុទ្ធសាសនា មកទេសនាពន្យល់ធម៌អាថ៌ព្រះពុទ្ធសាសនាក្នុងវិទ្យុនិងទូរទស្សន៍ ដើម្បីលើកដំកើងព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ស្របតាមគោលការណ៍... **តទៅទី២៨ (គ)**
របស់រាជរដ្ឋាភិបាល ដើម្បីឲ្យពុទ្ធបរិស័ទខ្មែរយល់កាន់តែច្បាស់ឡើង នូវធម៌របស់ព្រះពុទ្ធ ក្នុងការរួមវិភាគទាន បំបាត់ភាពក្រីក្រ និងអំពើហឹង្សាគ្រប់យ៉ាងក្នុងប្រទេសកម្ពុជា ។

៦- វិទ្យុនិងទូរទស្សន៍ជាឧបករណ៍សំខាន់ណាស់ ក្នុងការផ្សាយព្រះពុទ្ធសាសនា ដែលសម័យពុទ្ធកាលពុំទាន់កើតមាន ដើម្បីពង្រឹងព្រះពុទ្ធសាសនាឲ្យកាន់តែរឹង មាំឡើង ដើម្បីឲ្យសច្ចធម៌របស់ព្រះពុទ្ធ ដែលជាមាគ៌ាដ៏ត្រឹមត្រូវដឹកនាំសព្វសត្វឲ្យ ចេញចាកទុក្ខ ស្ថិតនៅជានិច្ចក្នុងសន្តានចិត្តខ្មែរគ្រប់រូបទប់ទល់នឹងសាសនាបរទេ- ស ដែលកំពុងព្យាយាមអូសទាញពុទ្ធសាសនិកជនជាពិសេសយុវជនខ្មែរ ឲ្យលះ បង់ព្រះពុទ្ធសាសនា ហើយចូលកាន់សាសនាគេវិញ ។

៧- ក្រសួងទាំងពីរគួរទប់ទល់វប្បធម៌បរទេស ដែលកំពុងផ្សាយបំផ្លាញវប្ប-ធម៌ខ្មែរ ។ វប្បធម៌បរទេសខ្លះជាវប្បធម៌អាសអាភៀស ដែលផ្ទុយពីវប្បធម៌ខ្មែរ ដែលមានសភាពសមរម្យនិងថ្លៃថ្នូរ ។ តែបែរជាក្រសួងទាំងពីរ រឹតបន្តឹងព្រះពុទ្ធសាសនា ដែលជាសាសនារបស់ប្រជាពលរដ្ឋខ្មែរទៅវិញ ។

ទី៨- ការចេញសារាចររបស់ក្រសួងធម៌ការ និងក្រសួងពត៌មាននេះ ជាការបិទបាំងមិនឲ្យនាយកខុទ្ទកាល័យសម្តេចសង្ឃរាជ ដែលជាតំណាងព្រះសង្ឃខ្មែរទូទាំងប្រទេសដឹងបានផងទេ នេះជាការរំលោភលើស្ថាប័នជាន់ខ្ពស់របស់ព្រះសង្ឃ ដែលជាស្ថាប័នមើលការខុសត្រូវលើព្រះសង្ឃ ។

ដូចបានពោលមកនេះបញ្ជាក់ថា ការចេញសារាចរនេះ ជាសារាចរខុសច្បាប់ផ្លូវពុទ្ធចក្រ និងខុសរដ្ឋធម្មនុញ្ញខ្មែរ ផ្លូវអាណាចក្រ អ្នកចាត់ការនិមន្តព្រះសង្ឃឲ្យទេស នាតាមវិទ្យុនិងទូរទស្សន៍ ពិតជាពុំគោរពតាមសារាចរនេះឡើយ ។ ដូច្នេះសូមក្រសួងទាំងពីរ ប្រកាសយ៉ាងណាកុំឲ្យសារាចរនេះមានសុពលភាពទៅមុខ ដើម្បីទុកលទ្ធភាពឲ្យវិទ្យុនិងទូរទស្សន៍នៅតែផ្សាយធម៌ទេសនាដូចធម្មតា ដោ-យមិនបាច់ឆ្លងកាត់ច្បាប់ និងការត្រួតពិនិត្យ ដូចមានចែងក្នុងសារាចរនេះ ។ បើទេ-សនាមានការខុសឆ្គង គ្រាន់តែសុំកែតម្រូវទុកជាការស្រេច នេះជាលក្ខណៈរបស់របបប្រជាធិបតេយ្យសេរី ដែលស្រុកជឿនលឿនក្នុងលោកធ្លាប់អនុវត្តមកហើយ ។

❑